**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ១៩ **អយក.** សណន

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងជ្រើសរើសសិស្សពូកែ ប្រចាំរាជធានី ខេត្ត និងទូទាំងប្រទេស សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣

ដើម្បីពង្រឹងគុណភាពអប់រំ និងអភិវឌ្ឍធនធានមនុស្សប្រកបដោយសីលធម៌ និងចំណេះដឹងខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំពីការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត និងទូទាំងប្រទេស នៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ សម្រាប់ឆ្នាំសិក្សា២០២២-២០២៣ តាមខ្លឹមសារដូចខាងក្រោមៈ

## ១. ការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការរៀបចំការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ និងថ្នាក់ទី១២ ដែលនឹងប្រព្រឹត្តទៅនៅក្នុងសប្តាហ៍ទី១ ខែមេសា ដើម្បីដណ្តើមជ័យលាភីថ្នាក់រាជធានី ខេត្ត តាមមុខវិជ្ជា តាមកម្រិតថ្នាក់ តាមចំនួនកំណត់ក្នុងតារាងបែងចែកជូនភ្ជាប់មកជាមួយនេះ រួចបញ្ជូនបេក្ខភាពមកចូលរួមប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវបែងចែកចំនួនបេក្ខជនចូលរួមប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត ទៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ និងឯកជន តាមសមាមាត្រចំនួនសិស្សជាក់ស្តែង តាមមុខវិជ្ជា តាមកម្រិតថ្នាក់។ ចំពោះគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅឯកជនដែលមានសិស្សតិចជាង ១០០នាក់ ត្រូវផ្តល់ចំនួនបេក្ខជនយ៉ាងតិច ០១នាក់ក្នុងមួយមុខវិជ្ជា ក្នុងមួយកម្រិតថ្នាក់ ប៉ុន្តែករណីនេះ គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅឯកជននោះ ត្រូវបង់ថវិកាចំនួន ៤០ ០០០រៀល(សែសិបពាន់រៀល) ក្នុងបេក្ខជន ០១នាក់ ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីរៀបចំការប្រឡង។

ដោយឡែកវិទ្យាល័យអនុវត្តនៃវិទ្យាស្ថានជាតិអប់រំ ត្រូវចូលរួមប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត ជាមួយគ្រឹះស្ថានមធ្យមសិក្សានានាក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ។

ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត ជាសមត្ថកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមី។ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈត្រូវផ្ញើសំណើប្រធានវិញ្ញាសា និងអត្រាកំណែសម្រាប់ការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត មុខវិជ្ជាអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា ដែលមានរយៈពេល ៣ម៉ោង និងវប្បធម៌ទូទៅ មានរយៈពេល ២ម៉ោង ថ្នាក់ទី៩ និងថ្នាក់ទី១២ មកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីធ្វើជាមូលដ្ឋានសម្រាប់រៀបចំប្រធានវិញ្ញាសា។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

នៅឆ្នាំសិក្សា២០២២-២០២៣នេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត អាចរៀបចំគណៈកម្មការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត តាមគំនិតច្នៃប្រឌិតផ្ទាល់ លទ្ធភាពថវិកា ឬតាមលំនាំនៃការរៀបចំកន្លងមក ដែលគិតតាមរបបបេសកកម្មក្នុងរាជធានី ខេត្ត ដូចខាងក្រោម៖

១. គណៈកម្មការរៀបចំការប្រឡង៖ ៥ថ្ងៃ

២. គណៈកម្មការគ្រប់គ្រង និងរៀបចំប្រធានវិញ្ញាសា៖ ៥ថ្ងៃ

៣. គណៈកម្មការតាក់តែងប្រធានវិញ្ញាសា (អក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា និងវប្បធម៌ទូទៅ ថ្នាក់ទី៩ និងថ្នាក់ទី១២)៖ ៥ថ្ងៃ

៤. ប្រធាន អនុប្រធានមណ្ឌលសំណេរ៖ ៣ថ្ងៃ

៥. គណៈកម្មការត្រួតពិនិត្យតាមអគារ៖ ៣ថ្ងៃ

៦. គណៈកម្មការកណ្តាល៖ ៣ថ្ងៃ

៧. គណៈកម្មការអនុរក្ស៖ ៣ថ្ងៃ

៨. ប្រធាន អនុប្រធានមណ្ឌលកំណែ៖ ៤ថ្ងៃ

៩. គណៈកម្មការបែងចែកសន្លឹកកិច្ចការ៖ ៤ថ្ងៃ

១០. គណៈកម្មការកំណែ៖ ៤ថ្ងៃ

១១. គណៈកម្មការស្រង់ បូកពិន្ទុ និងគូសជាប់ធ្លាក់៖ ២ថ្ងៃ

១២. គណៈកម្មការត្រួតពិនិត្យលទ្ធផលចុងក្រោយ៖ ១ថ្ងៃ

***សម្គាល់៖*** មន្ទីរអប់រំ យុវជន និងងកីឡាខេត្ត ត្រូវរៀបចំនិយាមប្រើប្រាស់គណៈមេប្រយោគតាមលទ្ធភាពជាក់ស្តែង និងមិនចាំបាច់រៀបចំឱ្យមានគ្រប់គណៈកម្មការប្រឡងទាំង១២ ដូចរៀបរាប់ខាងលើទេ។

## ២. ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

### ២.១.គោលការណ៍រួមនៃការប្រឡងជ្រើសរើសសិស្សពូកែ

#### ក.ការកំណត់កម្រិតថ្នាក់ វិញ្ញាសា និងសម័យប្រឡង

- ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសបានកំណត់យក ២កម្រិតថ្នាក់គឺ ថ្នាក់ទី៩ និងទី១២
- វិញ្ញាសាប្រឡងរួមមានផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា
- សម័យប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ត្រូវបានកំណត់យកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣
- ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយគិតតាមកម្មវិធីសិក្សាពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ សម្រាប់ការប្រឡងសិស្សពូកែថ្នាក់ទី៩ និងពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ សម្រាប់ការប្រឡងសិស្សពូកែថ្នាក់ទី១២។

#### ខ.ការរៀបចំពិធី និងមណ្ឌលប្រឡង

មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ដែលត្រូវធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស សម្រាប់ឆ្នាំ២០២៣ នេះ មានភារកិច្ច ៖

- រៀបចំវិទ្យាល័យ នេត យ៉ង់ សម្រាប់ធ្វើជាមណ្ឌលប្រឡងសិស្សពូកែទូទាំងប្រទេសឆ្នាំ២០២៣ និងរៀបចំទីកន្លែងសម្រាប់ប្រារព្ធពិធីបើក ពិធីបិទ ចែកវិញ្ញាបនបត្រ និងរង្វាន់ជ័យលាភីសិស្សពូកែទូទាំងប្រទេសឱ្យហើយស្រេច មុនបើកសម័យប្រឡងសិស្សពូកែ ដោយត្រូវសហការជាមួយនាយកដ្ឋានកិច្ចការប្រឡង
- អញ្ជើញអភិបាលរងនៃគណៈអភិបាលខេត្ត ដើម្បីថ្លែងសុន្ទរកថាស្វាគមន៍ក្នុងពិធីបើក និងអញ្ជើញ

អភិបាល នៃគណៈអភិបាលខេត្ត ដើម្បីជាអធិបតីក្នុងពិធីបិទ ចែកវិញ្ញាបនបត្រ និងរង្វាន់ជ័យលាភី និងអញ្ជើញភ្ញៀវចូលរួមជាកិត្តិយសរួមមាន អាជ្ញាធរមូលដ្ឋាន នគរបាល អាវុធហត្ថ និងមន្ទីរពាក់ព័ន្ធមួយចំនួននៅក្នុងខេត្ត

- ត្រូវសហការជាមួយនាយកដ្ឋានកិច្ចការប្រឡង ដើម្បីរៀបចំកម្មវិធីដំណើរកំសាន្តរបស់បេក្ខជន តាមរមណីយដ្ឋានកែច្នៃ ធម្មជាតិ វប្បធម៌ប្រវត្តិសាស្ត្រ ឬទីកន្លែងដែលមានសក្តានុពលផ្សេងទៀតនៅក្នុងខេត្ត ហើយត្រូវធ្វើលិខិតទៅអាជ្ញាធរខេត្ត ដើម្បីស្នើសុំជួយអន្តរាគមន៍ និងស្នើសុំកម្លាំងសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានជួយរក្សាសន្តិសុខ និងជួយសម្របសម្រួលការងារផ្សេងៗ សំដៅធ្វើឱ្យដំណើរកំសាន្តនេះ ប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងបរិយាកាសរីករាយ។

**គ.លក្ខខណ្ឌសម្រាប់បេក្ខជនសិស្សពូកែ**

- បេក្ខជនសិស្សពូកែទាំងអស់ ត្រូវស្លៀកពាក់ជាឯកសណ្ឋានសិស្ស ដោយប្រើអាវពណ៌ស និងខោ ឬសំពត់ពណ៌ខៀវ។ អាវត្រូវស៊កចូលក្នុងខោ ឬសំពត់ឱ្យបានត្រឹមត្រូវ ហើយត្រូវពាក់ប័ណ្ណសម្គាល់ខ្លួននៅពេលចូលមណ្ឌលប្រឡង និងត្រូវពាក់ម៉ាស់ចូលរួមពិធីបើក និងបិទការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស
- បេក្ខជនសិស្សពូកែម្នាក់ៗ អាចជ្រើសរើសមុខវិជ្ជាឯកទេស ដើម្បីធ្វើការប្រឡងបានតែមួយមុខវិជ្ជាប៉ុណ្ណោះ ក្នុងចំណោមអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា។ ចំណែកមុខវិជ្ជាវប្បធម៌ទូទៅ ជាមុខវិជ្ជាដែលបេក្ខជនម្នាក់ៗ ត្រូវបំពេញឱ្យគ្រប់លក្ខខណ្ឌនៃការប្រឡងជ្រើសរើស។ បេក្ខជនម្នាក់ៗ ត្រូវធ្វើកិច្ចការប្រឡងជាបីពេល គឺមុខវិជ្ជាឯកទេសដែលខ្លួនបានជ្រើសរើសចំនួនពីរពេល និងមុខវិជ្ជាវប្បធម៌ទូទៅចំនួនមួយពេល
- បេក្ខជនសិស្សពូកែត្រូវបានអនុញ្ញាតឱ្យប្រើម៉ាស៊ីនគិតលេខ ដែលគណៈកម្មការរៀបចំការប្រឡងបានត្រៀមបម្រុងទុកឱ្យខ្ចីប្រើជាស្រេចសម្រាប់បេក្ខជនសិស្សពូកែមុខវិជ្ជារូបវិទ្យាថ្នាក់ទី៩ និងថ្នាក់ទី១២។

**ឃ.ការគ្រប់គ្រងបេក្ខជនសិស្សពូកែ**

ប្រតិភូប្រចាំរាជធានី ខេត្តនីមួយៗ មានភារកិច្ចៈ

- ដឹកនាំ គ្រប់គ្រងបេក្ខជនសិស្សពូកែរបស់ខ្លួន ចាប់តាំងពីពេលចេញដំណើរពីរាជធានី ខេត្តសាមី រហូតដល់ពេលត្រឡប់ទៅរាជធានី ខេត្តរៀងៗខ្លួនវិញ
- រៀបចំការហូបចុក និងស្នាក់នៅរបស់បេក្ខជនសិស្សពូកែ ឱ្យបានសមស្របតាមគោលការណ៍ចំណាយរបស់ក្រសួង ជាពិសេសត្រូវចុះជាប់ជាមួយសិស្សនៅពេលធ្វើដំណើរកំសាន្ត ចៀសវាងដាច់ខាតកុំឱ្យកើតមានបញ្ហាជាយថាហេតុ។

## ២.២-ការប្រព្រឹត្តទៅនៃដំណើរការប្រឡង

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | *ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣ | *ពេលព្រឹកៈ ប្រារព្ធពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសនៅក្នុងបរិវេណវិទ្យាល័យ នេត យ៉ង់ ឬទីកន្លែងផ្សេងទៀតតាមការចាំបាច់ក្នុងខេត្តបាត់ដំបង វេលាម៉ោង ៨:០០នាទី។<br>*ពេលរសៀលៈ ប្រធាន អនុប្រធានមណ្ឌលប្រជុំណែនាំសមាជិកគណៈមេប្រយោគនៅមណ្ឌលវិទ្យាល័យ នេត យ៉ង់ វេលាម៉ោង ១៤:០០នាទី។ |
| ២ | *ថ្ងៃទី១២ | *ពេលព្រឹកៈ - ដំណើរការសំណេរវិញ្ញាសាទី១ មុខវិជ្ជាអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និង |

| | | |
|---|---|---|
| | ខែមិថុនា ឆ្នាំ២០២៣ | រូបវិទ្យា ថ្នាក់ទី៩ និងថ្នាក់ទី១២<br>- គណៈកម្មការកំណែ ៖ ធ្វើអត្រាកំណែតាមមុខវិជ្ជា តាមកម្រិតថ្នាក់<br>- គណៈកម្មការកណ្ដាលកំណែ ៖ ពិនិត្យផ្ទៀងផ្ទាត់ កាត់ក្បាលសន្លឹកកិច្ចការបេក្ខជន និងចុះអក្សរសម្ងាត់លើសន្លឹកកិច្ចការបេក្ខជន។<br>***ពេលរសៀល៖** កែកិច្ចការបេក្ខជន។ |
| ៣ | *ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ | ***ពេលព្រឹក៖** - ដំណើរការសំណេរវិញ្ញាសាវប្បធម៌ទូទៅថ្នាក់ទី៩ និងថ្នាក់ទី១២<br>- គណៈកម្មការកំណែ៖ ធ្វើអត្រាកំណែមុខវិជ្ជាវប្បធម៌ទូទៅតាមកម្រិតថ្នាក់ និងបន្តកែកិច្ចការបេក្ខជនតាមមុខវិជ្ជាឯកទេសរៀងៗខ្លួន<br>- គណៈកម្មការកណ្ដាលកំណែ៖ ពិនិត្យផ្ទៀងផ្ទាត់ កាត់ក្បាលសន្លឹកកិច្ចការបេក្ខជន និងចុះអក្សរសម្ងាត់លើសន្លឹកកិច្ចការបេក្ខជន។<br>***ពេលរសៀល៖** កែកិច្ចការបេក្ខជន។ |
| ៤ | *ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ | ***ពេលព្រឹក៖** - ដំណើរការសំណេរវិញ្ញាសាទី២ មុខវិជ្ជាអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ និងទី១២<br>- គណៈកម្មការកំណែ៖ ធ្វើអត្រាកំណែតាមមុខវិជ្ជា តាមកម្រិតថ្នាក់ និងកែបន្ត<br>- គណៈកម្មការកណ្ដាលកំណែ៖ ពិនិត្យផ្ទៀងផ្ទាត់ កាត់ក្បាលសន្លឹកកិច្ចការបេក្ខជន និងចុះអក្សរសម្ងាត់លើសន្លឹកកិច្ចការបេក្ខជន។<br>***ពេលរសៀល៖** កែកិច្ចការបេក្ខជន។ |
| ៥ | *ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ | - បន្តកែកិច្ចការបេក្ខជន<br>- នាំបេក្ខជនសិស្សពូកែធ្វើដំណើរកំសាន្តតាមរមណីយដ្ឋានកែច្នៃ ធម្មជាតិ និងវប្បធម៌។ |
| ៦ | *ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ | - បន្តកែកិច្ចការបេក្ខជន<br>- ស្រង់ បូកពិន្ទុ និងពិនិត្យផ្ទៀងផ្ទាត់ពិន្ទុ<br>- នាំបេក្ខជនសិស្សពូកែធ្វើដំណើរកំសាន្តតាមរមណីយដ្ឋានកែច្នៃ ធម្មជាតិ និងវប្បធម៌។ |
| ៧ | *ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ | - គណៈកម្មការគ្រប់គ្រងទូទៅប្រជុំសម្រេចលទ្ធផលប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស<br>- ក្រោយពេលប្រជុំសម្រេចរួច គណៈកម្មការកណ្ដាលកំណែត្រូវបោះពុម្ព៖<br>+ បញ្ជីស្ថិតិលទ្ធផលសិស្សពូកែតាមរាជធានី ខេត្ត<br>+ បញ្ជីចំណាត់ថ្នាក់សិស្សពូកែទូទាំងប្រទេសតាមមុខវិជ្ជា និងកម្រិតថ្នាក់<br>+ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេសពីលេខ១ ដល់លេខ១០<br>+ វិញ្ញាបនបត្រជ័យលាភីសិស្សពូកែទូទាំងប្រទេសពីលេខ១ ដល់លេខ១០<br>- រៀបចំពិធីបិទការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស។ |
| ៨ | *ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ | ***រៀបចំពិធីបិទ៖**<br>ពិធីចែកវិញ្ញាបនបត្រ និងចែករង្វាន់ជ័យលាភីសិស្សពូកែទូទាំងប្រទេស ប្រចាំឆ្នាំ២០២៣ នៅវិទ្យាល័យ នេត យ៉ង់ ខេត្តបាត់ដំបង វេលាម៉ោង៨:០០នាទីព្រឹក ។ |

**២.៣- រយៈពេល និងរបបពិន្ទុ នៃវិញ្ញាសាប្រឡងនីមួយៗ ថ្នាក់ទី៩ និងថ្នាក់ទី១២**

| | | | |
|---|---|---|---|
| – | អក្សរសិល្ប៍ខ្មែរ៖ | ១៨០នាទី | ១០០ពិន្ទុ |
| – | គណិតវិទ្យា ៖ | ១៨០នាទី | ១០០ពិន្ទុ |
| – | រូបវិទ្យា ៖ | ១៨០នាទី | ១០០ពិន្ទុ |
| – | វប្បធម៌ទូទៅ ៖ | ១២០នាទី | ១០០ពិន្ទុ។ |

**២.៤- សំណុំលិខិតរបស់បេក្ខជន**

ក្រោយពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តបានប្រកាសលទ្ធផលរួច សិស្សដែលបានជាប់ជាបេក្ខជនសិស្សពូកែប្រចាំរាជធានី ខេត្ត ត្រូវរៀបចំបំពេញសំណុំលិខិត ដើម្បីចូលរួមប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ដូចខាងក្រោម៖

- ពាក្យសុំចុះឈ្មោះប្រឡងសិស្សពូកែទូទាំងប្រទេស (គំរូទី១)
- សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត(ថតចម្លង) សម្រាប់សិស្សថ្នាក់ទី៩ និងថ្នាក់ទី១២
- វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិ(ថតចម្លង) សម្រាប់សិស្សថ្នាក់ទី១២។

*បន្ទាប់ពីបានទទួលសំណុំលិខិតបេក្ខជនរួច ការិយាល័យជំនាញរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវ៖

- ➢ ប្រើកម្មវិធីគ្រប់គ្រងទិន្នន័យសិស្សពូកែ សម្រាប់បញ្ចូលទិន្នន័យបេក្ខជនសិស្សពូកែ
- ➢ ប្រើ Digital Camera សម្រាប់ថតរូបបេក្ខជន ដោយតម្រូវឱ្យបេក្ខជនពាក់អាវស មានបិទស្លាកឈ្មោះនៅលើអាវផ្នែកខាងលើ ឆ្វេង រួចនាំរូបថតបេក្ខជនចូលទៅក្នុងកម្មវិធីគ្រប់គ្រងទិន្នន័យសិស្សពូកែ
- ➢ បោះពុម្ពបញ្ជីសំណើបេក្ខភាពប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស(គំរូទី២)។

*ការិយាល័យជំនាញនៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តត្រូវផ្ញើមកនាយកដ្ឋានកិច្ចការប្រឡងនូវសំណុំឯកសារដូចខាងក្រោម៖

១.សំណុំលិខិតបេក្ខជនប្រឡងសិស្សពូកែ

២.បញ្ជីសំណើបេក្ខភាពប្រឡងសិស្សពូកែទូទាំងប្រទេស

៣.Soft Data សិស្សពូកែប្រចាំរាជធានី ខេត្ត

*កាលបរិច្ឆេទផុតកំណត់ទទួលសំណុំឯកសារ៖ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣

*នាយកដ្ឋានកិច្ចការប្រឡង៖ ស្ថិតនៅអគារលេខ ១៦៩ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ឬតាម Telegram: ការិយាល័យប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រឡង ទូរស័ព្ទលេខ ០៧៨ ៧២ ៧០ ៤៦។

**២.៥- លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសជ័យលាភីសិស្សពូកែ**

- បេក្ខជនណាមិនគោរពបទបញ្ញត្តិនៃការប្រឡង ដូចជាលួចមើលសំណៅផ្សេងៗ ងាកមើលអ្នកជិតខាង ឬសួរគ្នា នឹងត្រូវជម្រុះចោល
- បេក្ខជនណាដែលមានពិន្ទុវប្បធម៌ទូទៅក្រោមមធ្យមភាគ នឹងត្រូវជម្រុះចោល ប៉ុន្តែពិន្ទុវប្បធម៌ទូទៅមិនត្រូវបានយកទៅបូកនឹងពិន្ទុមុខវិជ្ជាឯកទេសឡើយ

- បេក្ខជនណាដែលមានពិន្ទុវប្បធម៌ទូទៅលើមធ្យមភាគ និងពិន្ទុសរុបមុខវិជ្ជាឯកទេសលើមធ្យមភាគ ត្រូវបានកំណត់ជាជម្រើសសម្រាប់ប្រជែងជាជ័យលាភីសិស្សពូកែតាមមុខវិជ្ជាឯកទេស តាមកម្រិតថ្នាក់ ដោយជ្រើសយកពីលំដាប់ពិន្ទុខ្ពស់មកទាប ជាបន្តបន្ទាប់រហូតដល់ចំណាត់ថ្នាក់លេខ១០
- ក្នុងករណីដែលការជ្រើសរើសបេក្ខជនសម្រាប់ប្រជែងជាជ័យលាភីសិស្សពូកែ តាមមុខវិជ្ជាឯកទេស តាមកម្រិតថ្នាក់មិនបានគ្រប់ចំនួនតាមតម្រូវការដូចលក្ខខណ្ឌចែងក្នុងចំណុចទី៣ គណៈគ្រប់គ្រងទូទៅនៃការប្រឡងសិស្សពូកែទូទាំងប្រទេស ត្រូវប្រជុំសម្រេច ដើម្បីស្រង់យកបេក្ខជនជ័យលាភីបន្ថែមឱ្យគ្រប់ ១០នាក់ក្នុង មួយមុខវិជ្ជា និងមួយកម្រិតថ្នាក់
- ក្នុងករណីពិន្ទុសរុបមុខវិជ្ជាឯកទេសស្មើគ្នា ត្រូវអញ្ជើញប្រធាន ឬអនុប្រធានកំណែមកកែកិច្ចការនោះសាជាថ្មីឡើងវិញ តាមបែបកំណែសម្ងាត់
- ក្នុងករណីកែឡើងវិញ ពិន្ទុនៅតែស្មើគ្នាទៀត ត្រូវសម្រេចផ្ដល់អាទិភាពជូនបេក្ខជនជានារី
- គ្រប់សន្លឹកកិច្ចការបេក្ខជន ត្រូវកែជារបៀបសម្ងាត់ទាំងអស់។ សន្លឹកកិច្ចការបេក្ខជនម្នាក់ៗ ត្រូវកែដោយអ្នកកែពីរនាក់ផ្សេងៗគ្នា ដោយដាក់ពិន្ទុសម្ងាត់រៀងៗខ្លួន ហើយពិន្ទុនោះមិនត្រូវសរសេរលើសន្លឹកកិច្ចការបេក្ខជនឡើយ។ ក្រោយពីកែរួច អ្នកកែត្រូវយករបាយពិន្ទុលម្អិតជាសម្ងាត់នោះ មកប្រគល់ជូនប្រធានក្រុមកំណែដើម្បីបញ្ជូនទៅគណៈកម្មការកណ្ដាលកំណែ។ របាយពិន្ទុលម្អិតរបស់អ្នកកែទាំងពីរនាក់ សម្រាប់សន្លឹកកិច្ចការបេក្ខជនម្នាក់ នឹងត្រូវយកមកផ្ទៀងផ្ទាត់ឡើងវិញ
- ក្នុងករណីគម្លាតពិន្ទុរវាងអ្នកកែទាំងពីរៈ
  - មុខវិជ្ជាអក្សរសិល្ប៍ខ្មែរ និងវប្បធម៌ទូទៅៈ ក្រោម ឬស្មើ ១០ពិន្ទុ
  - មុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យាៈ ក្រោម ឬស្មើ៥ពិន្ទុត្រូវសម្រេចយកមធ្យមភាគនៃពិន្ទុរបស់អ្នកកែទាំងពីរ ប៉ុន្តែក្នុងករណីគម្លាតពិន្ទុរវាងអ្នកកែទាំងពីរៈ
  - មុខវិជ្ជាអក្សរសិល្ប៍ខ្មែរ និងវប្បធម៌ទូទៅៈ ធំជាង ១០ពិន្ទុ
  - មុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យាៈ ធំជាង ៥ ពិន្ទុ ត្រូវរៀបចំឱ្យកែជាលក្ខណៈសម្ងាត់ឡើងវិញ។

## ២.៦-ផលប្រយោជន៍ដែលជ័យលាភីត្រូវទទួលបាន

បេក្ខជនគ្រប់រូប ត្រូវទទួលបានវិញ្ញាបនបត្រចូលរួមប្រឡងសិស្សពូកែទូទាំងប្រទេស ម្នាក់មួយសន្លឹក។ ចំណែកឯបេក្ខជនជ័យលាភីសិស្សពូកែទូទាំងប្រទេស ត្រូវទទួលបានរង្វាន់ និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា ដូចខាងក្រោមៈ

- ប្រកាសស្ដីពីការទទួលស្គាល់សិស្សពូកែដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មួយច្បាប់
- មេដាយមួយគ្រឿង សម្រាប់បេក្ខជនជ័យលាភី ចំណាត់ថ្នាក់ពីលេខ១ ដល់លេខ៣
- វិញ្ញាបនបត្របញ្ជាក់សិស្សពូកែទូទាំងប្រទេស មួយច្បាប់
- ប្រាក់រង្វាន់តាមចំណាត់ថ្នាក់ៈ
  - ចំណាត់ថ្នាក់លេខ១ ៣ ៥០០ ០០០ (បីលានប្រាំរយពាន់)រៀល
  - ចំណាត់ថ្នាក់លេខ២ ៣ ២០០ ០០០ (បីលានពីររយពាន់)រៀល
  - ចំណាត់ថ្នាក់លេខ៣ ២ ៩០០ ០០០ (ពីរលានប្រាំបួនរយពាន់)រៀល
  - ចំណាត់ថ្នាក់លេខ៤ ២ ៦០០ ០០០ (ពីរលានប្រាំមួយរយពាន់)រៀល
  - ចំណាត់ថ្នាក់លេខ៥ ២ ៣០០ ០០០ (ពីរលានបីរយពាន់)រៀល
  - ចំណាត់ថ្នាក់លេខ៦ ២ ០០០ ០០០ (ពីរលាន)រៀល
  - ចំណាត់ថ្នាក់លេខ៧ ១ ៧០០ ០០០ (មួយលានប្រាំពីររយពាន់)រៀល

- ○ ចំណាត់ថ្នាក់លេខ៨ ១ ៤០០ ០០០(មួយលានបួនរយពាន់)រៀល
- ○ ចំណាត់ថ្នាក់លេខ៩ ១ ១០០ ០០០ (មួយលានមួយរយពាន់)រៀល
- ○ ចំណាត់ថ្នាក់លេខ១០ ៨០០ ០០០ (ប្រាំបីរយពាន់)រៀល

***សម្គាល់៖** បេក្ខជនជ័យលាភីសិស្សពូកែទូទាំងប្រទេស អាចមានប្រាក់រង្វាន់ ឬវត្ថុផ្សេងៗបន្ថែមទៀតពីសប្បុរសជន។

## ២.៧-ការចំណាយ និងពេលវេលាត្រូវទៅដល់កន្លែងប្រារព្ធពិធីរបស់បេក្ខជនសិស្សពូកែ និងគណៈប្រតិភូ រាជធានី ខេត្ត

ប្រតិភូដឹកនាំសិស្សពូកែទូទាំងប្រទេសតាមរាជធានី ខេត្ត ត្រូវ៖

- នាំសិស្សទៅដល់ទីរួមខេត្តបាត់ដំបង នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣
- ចូលរួមប្រារព្ធពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស នៅវិទ្យាល័យ នេត យ៉ង់ ខេត្តបាត់ដំបង នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ៨:០០នាទីព្រឹក
- ការចំណាយក្នុងដំណើរការប្រឡង ការរៀបចំពិធីបើកការប្រឡង ពិធីបិទ ចែកវិញ្ញាបនបត្រ និងចែករង្វាន់ជ័យលាភី សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុក និងដំណើរកំសាន្តរបស់បេក្ខជន ជាបន្ទុករបស់ក្រសួងអប់រំ យុវជន និងកីឡា។

សូមជូនភ្ជាប់មកជាមួយនូវ៖

- ➢ តារាងបែងចែកបេក្ខជនសិស្សពូកែ និងប្រតិភូតាមរាជធានី ខេត្ត
- ➢ ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស (គំរូទី១)
- ➢ បញ្ជីសំណើបេក្ខភាពប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស (គំរូទី២)។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ផ្សព្វផ្សាយដល់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជនក្នុងរាជធានី ខេត្ត ព្រមទាំងអនុវត្តសេចក្តីណែនាំនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ពុធ ១១រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលារាជធានី ខេត្ត
-អង្គភាពក្រោមឱវាទក្រសួង អយក
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
" ដើម្បីជ្រាបជាព័ត៌មាន "
-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
-គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន
" ដើម្បីអនុវត្ត "
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានកិច្ចការប្រឡង